# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អជសជ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ២០១១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 03-Jun-2011, 12:32
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬអង្គជំនុំជម្រះ : **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើរបស់ អៀង សារី សុំឲ្យដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿង (CaseMap) នៅក្នុងសំណុំរឿង

---

ដាក់ដោយ៖

**សហមេធាវីរបស់លោក អៀង សារី៖**

អាង ឧត្តម

Michael G. KARNAVAS

ផ្ញើជូន៖

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម ធូ មុនី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង យូ ឧត្តារ៉ា

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា៖**

---

ជា លាង

Andrew CAYLEY

ក្រុមមេធាវីការពារក្ដីទាំងអស់

ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់

លោក អៀង សារី តាមរយៈសហមេធាវីរបស់ខ្លួន (“មេធាវីការពារក្តី”) អនុលោមតាមវិធាន ៨៦ និង ២១ នៃវិធានផ្ទៃក្នុង អ.វ.ត.ក (“វិធាន”) សូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងដាក់ប្រព័ន្ធគ្រប់គ្រងសំណុំរឿង (CaseMap) របស់ ក.ស.ច.ស ចូលទៅក្នុងសំណុំរឿង។ សំណើនេះមានសារៈសំខាន់ ពីព្រោះភាគីមានសិទ្ធិពិនិត្យប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស។ ជាការសមស្រប ត្រូវចាត់ទុកប្រព័ន្ធគ្រប់គ្រងសំណុំរឿងថាជាផ្នែកនៃសំណុំរឿង ហើយអនុលោម តាមវិធាន ៨៦ ភាគីមានសិទ្ធិពិនិត្យមើល និងថតចម្លងសំណុំរឿង ។ សិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្តីឲ្យបានឆាប់រហ័ស និងសិទ្ធិរបស់គាត់ក្នុងការទទួលបានសម្ភារៈរូបវន្តគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន តម្រូវថាត្រូវដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ទៅក្នុងសំណុំរឿង។ ប្រសិនបើប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ត្រូវបានផ្តល់ទៅឲ្យអង្គជំនុំជម្រះសាលាដំបូង ប្រការនេះនឹងគាំទ្រគោលជំហររបស់មេធាវីការពារក្តីដែលថាភាគីទាំងអស់មានសិទ្ធិពិនិត្យប្រព័ន្ធគ្រប់គ្រងសំណុំរឿងបាន។

## I. សេចក្តីផ្តើមទាក់ទិននឹងប្រព័ន្ធគ្រប់គ្រងសំណុំរឿង

១. ប្រព័ន្ធគ្រប់គ្រងសំណុំរឿង (CaseMap) គឺជាកម្មវិធីគ្រប់គ្រងបណ្តឹងដែលត្រូវបានបង្កើតឡើងដើម្បីជួយរៀបចំសំណុំរឿងដែលមានលក្ខណៈស្មុគស្មាញ។ បើសិនជាយើងប្រើប្រាស់ពាក្យនៅប្រព័ន្ធគ្រប់គ្រងសំណុំរឿងតែម្តង “អង្គហេតុ” (ជា ព្រឹត្តការណ៍) ត្រូវបានភ្ជាប់ជាមួយនឹង “កម្មវត្ថុ” (ជាទីកន្លែង ឯកសារ បុគ្គលសំខាន់ៗ) និង “បញ្ហា” ដើម្បីសម្រួលដល់ការស្រាវជ្រាវដ៏ប៉ិនប្រសប់ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យទាំងនេះ។ ម៉្យាងវិញទៀត ប្រព័ន្ធគ្រប់គ្រងសំណុំរឿងនេះអាចជួយឲ្យអ្នកប្រើប្រាស់ស្រាវជ្រាវរកឯកសារ និងភ្ជាប់ឯកសារជាមួយនឹងអង្គហេតុ និងបញ្ហានានានៅក្នុងសំណុំរឿង[1]។

២. នៅ អ.វ.ត.ក ប្រព័ន្ធគ្រប់គ្រងសំណុំរឿង ត្រូវបានប្រើប្រាស់ដោយ ក.ស.ច.ស និង (តាមដែលមេធាវីការពារក្តីដឹង) ដោយអង្គជំនុំជម្រះសាលាដំបូង។ មេធាវីការពារក្តីយល់ថា ក.ស.ច.ស បានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងសំណុំរឿង ដើម្បីធ្វើ*កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចស៊ើបសួរ* រួមទាំងកំណត់

---

[1] សូមមើល*See* http://www.casesoft.com/casemap/casemap.asp

ហេតុនៃការស្តាប់ចម្លើយសាក្សី ការចុះទៅពិនិត្យកន្លែងកើតហេតុ និងការវិភាគផ្នែកច្បាប់/អង្គហេតុ។ ដីកាដំណោះស្រាយប្រាកដជាឆ្លុះបញ្ចាំង ឬជាអនុផលនៃប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស។

## II. **សារធាតុ**

៣. នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ការបំពេញកិច្ចស៊ើបសួរលើលោក អៀង សារី ត្រូវបានចាប់ផ្តើមឡើង ដោយមានការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពី ក.ស.ព[2]។

៤. នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១០ ក.ស.ច.ស បានជូនដំណឹងដល់ភាគី និងមេធាវីរបស់ពួកគេថា សហចៅក្រមស៊ើបអង្កេតចាត់ទុកថា កិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០២ ត្រូវបានបញ្ចប់សព្វគ្រប់ហើយ[3]។ នៅត្រឹមកាលបរិច្ឆេទនោះដែរ "ឯកសារភ័ស្តុតាងរាប់ពាន់ទំព័រ ត្រូវបានដាក់ទៅក្នុងសំណុំរឿង។ ចម្លើយចំនួន ៨០០ របស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងជនត្រូវចោទ ត្រូវបានស្តាប់ ដោយចៅក្រម និងអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស។ ដីកាចាត់ឲ្យស៊ើបសួរជំនួសជាតិ ឬអន្តរជាតិ ចំនួន ៥៣ ត្រូវបានចេញឲ្យអនុវត្ត។ សេចក្តីសម្រេចចំនួន ២០០ ត្រូវបានចេញ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាង ២.០០០ ត្រូវបានទទួល..."[4]។

៥. នៅថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១០ មេធាវីការពារក្តីបានស្នើឲ្យ ក.ស.ច.ស ផ្តល់ឲ្យខ្លួន *ក្នុងចំណោមនោះ* គឺប្រព័ន្ធគ្រប់គ្រងសំណុំរឿង CaseMap[5]។ មេធាវីការពារក្តីបានលើកទឡ្ហីករណ៍ ថា ៖

> ការពិនិត្យប្រព័ន្ធគ្រប់គ្រងសំណុំរឿង (CaseMap) និងការងារផ្ទៃក្នុងពាក់ព័ន្ធផ្សេងទៀត គឺជាការចាំបាច់មួយសម្រាប់មេធាវីការពារក្តីក្នុងការអនុវត្តសកម្មភាពនានា *ក្នុងចំណោម*

---

[2] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារ D3 ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៧។

[3] សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១០ ឯកសារ D317។

[4] សូមមើល សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "ការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០២" អាចរកមើលបាននៅគេហទំព័រ http://www.eccc.gov.kh/en/articles/conclusion-judicial-investigation-case-002

[5] សំណើសុំពិនិត្យមើលសំណុំរឿងទាំងមូល រួមទាំងឯកសារទាំងអស់ដែលលោកមាន ប៉ុន្តែគូភាគីពុំទាន់បានទទួល និងប្រព័ន្ធគ្រប់គ្រងសំណុំរឿង បើសិនជាបានរៀបចំធ្វើ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១០ ឯកសារ D354។

*សកម្មភាពផ្សេងទៀត* ដូចមានរៀបរាប់ខាងក្រោម សំដៅគាំពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក អៀង សារី ៖

- ពិនិត្យមើលថាតើគួរស្នើឲ្យ ក.ស.ច.ស បំពេញកិច្ចស៊ើបសួរបន្ថែមទៀតដែរ ឬយ៉ាងណា?
- ពិនិត្យមើលថាតើកិច្ចស៊ើបសួរត្រូវបាន ក.ស.ច.ស បំពេញប្រកបដោយអនាគតិដែរឬទេ?
- ពិនិត្យមើលកម្រិតនៃការពឹងផ្អែកទៅលើភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម។
- ជាប្រយោជន៍ដល់ការសន្សំសំចៃថវិកាតុលាការ និងសមភាពនៃមធ្យោបាយនៃការតទល់ក្តី (equality of arms)។

ប្រសិនបើមេធាវីការពារក្តីបានដឹងអំពីសំណុំរឿងប្រឆាំងនឹងលោក អៀង សារី កាន់តែឆាប់ នោះកិច្ចដំណើរការនីតិវិធីនឹងកាន់តែមានភាពយុត្តិធម៌។

៦. នៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១០ សំណើនេះត្រូវបានបដិសេធ ហើយ ក.ស.ច.ស បានចេញសេចក្តីព្រមានដល់មេធាវីការពារក្តីក្នុងការដាក់សំណើសុំច្រំដែល[6]។

[6] សូមមើល ដីកាសម្រេចធ្វើការព្រមាន ដោយអនុលោមតាមវិធាន ៣៨ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១០ ឯកសារ D367 កថាខណ្ឌ ១០(ខ), ១៤, ១៥។ ក.ស.ច.ស បានធ្វើការព្រមានមេធាវីការពារក្តី ដោយផ្អែកលើមូលដ្ឋានបីផ្សេងគ្នា ៖ **ក.** មិនគោរពវិធានសម្រាប់ការដាក់ឯកសារ **ខ.** មិនគោរពប្រព័ន្ធនីតិវិធីពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ **គ.** ការដាក់សំណើច្រំដែល និងបញ្ហាដែលត្រូវបានដោះស្រាយតាមផ្លូវតុលាការរួចមកហើយ។ នៅក្នុងបរិបទនៃសំណើនេះ វាមានការសង្កត់ធ្ងន់យ៉ាងជាក់លាក់ថា មេធាវីការពារក្តីមិនត្រូវបានព្រមានចំពោះការបង្ហាញនូវការមិនគោរពប្រព័ន្ធនីតិវិធីពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ ចំពោះការស្នើសុំប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ឡើយ។ នៅក្នុងការបដិសេធទៅលើសំណើសុំពិនិត្យព័ត៌មានដែលពាក់ព័ន្ធកាលពីពេលកន្លងមក ក.ស.ច.ស បានលើកយកវិធាន ៧០ (ក) នៃ វិធានរបស់តុលាការ ICTY ស្តីពីនីតិវិធី និងភស្តុតាងមកធ្វើជាសំអាង ៖ "បើទោះជាមានបទប្បញ្ញត្តិនៃវិធាន ៦៦ និង ៦៧ ក្តី ក៏របាយការណ៍ អនុស្សារណៈ ឬឯកសារផ្ទៃក្នុងផ្សេងៗ ដែលភាគី ជំនួយការ ឬអ្នកតំណាង ទាក់ទិននឹងកិច្ចស៊ើបសួរ ឬការរៀបចំសំណុំរឿង ដែលបានរៀបចំឡើង មិនមែនជាកម្មវត្ថុដែលត្រូវផ្សព្វផ្សាយ ឬជូនដំណឹង តាមវិធានទាំងនេះឡើយ"។ ការិយាល័យសហចៅក្រមស៊ើបអង្កេត "សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ" ពាក់ព័ន្ធដូចជាយុទ្ធសាស្ត្រអនុវត្តដោយការិយាល័យសហ

៧. នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ ក.ស.ច.ស បានដាក់ដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២[7]។ មានឯកសារចំនួន ១.៧៦២ ពីសំណុំរឿងដែលត្រូវបានយកធ្វើជាសំអាងនៅក្នុងដីកាដំណោះស្រាយ[8]។ នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ[9]។ នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង ០០២[10]។ នៅត្រឹមថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១១ ក្នុងសំណុំរឿង ០០២ មានឯកសារចំនួន ៧០.៨១៩ នៅក្នុងសំណុំរឿង។

៨. មេធាវីការពារក្តីបានយល់ថា ចាប់តាំងពីទទួលបានសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូងកំពុងបង្កើតប្រព័ន្ធគ្រប់គ្រងសំណុំរឿង។ នេះដោយសារតែមេធាវីការពារក្តីយល់ថា អង្គជំនុំជម្រះសាលាដំបូងអាចបានរក្សាទុកបុគ្គលិកដែលកាលពីមុនបានប្រើងប្រែង ឬដែលបានជួយក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស។

## III. ច្បាប់

---

ចៅក្រមស៊ើបអង្កេត ឯកសារ D171/5 ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០០៩ ដូចខាងលើ កថាខណ្ឌ ២៣ ជើងទំព័រ ១២។ ប៉ុន្តែសូមមើលសំណើសុំពិនិត្យមើលសំណុំរឿងទាំងមូល រួមទាំងឯកសារទាំងអស់ដែលលោកមាន ប៉ុន្តែគូភាគីពុំទាន់បានទទួល និងប្រព័ន្ធគ្រប់គ្រងសំណុំរឿង បើសិនជាបានរៀបចំធ្វើ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១០ ឯកសារ D354 ដែលមេធាវីការពារក្តីលើកទឡ្ហីករណ៍ថា ៖ "អ.វ.ត.ក ប្រើប្រព័ន្ធជជីកសួរដេញដោលដោយចៅក្រម (inquisitorial system) ... តុលាការ ICTY ប្រើប្រព័ន្ធឱ្យគូក្តីតទល់គ្នា (adversarial system) ដោយអនុញ្ញាតឱ្យភាគីព្រះរាជអាជ្ញា និងមេធាវីការពារក្តីអាច អនុវត្តកិច្ចស៊ើបសួរខ្លួនឯងដោយឡែក។ គោលបំណងនៃវិធាន ៧០(ក) នៅឯតុលាការ ICTY គឺដើម្បីការពារភាពសម្ងាត់របស់ភាគី នីមួយៗ នៅពេលរៀបចំសំណុំរឿងរៀងៗខ្លួន។ ប៉ុន្តែនៅ អ.វ.ត.ក កិច្ចស៊ើបសួរត្រូវបានបំពេញដោយ ក.ស.ច.ស សម្រាប់គ្រប់ភាគី ពាក់ព័ន្ធទាំងអស់។ ភាពសម្ងាត់គួរតែពុំមែនជាបញ្ហាចោទឡើយ។ អាស្រ័យហេតុនេះ វិធាន ៧០(ក) របស់តុលាការ ICTY ពុំត្រឹមតែពុំអាចយកមកអនុវត្តបាននោះទេ ប៉ុន្តែថែមទាំងពុំមានភាពចាំបាច់សម្រាប់ អ.វ.ត.ក ឡើយ"។

[7] ដីកាដំណោះស្រាយ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D427។

[8] ដូចជើងទំព័រខាងលើ។

[9] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០១១ ឯកសារ D427/1/26។

[10] ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០១១ ឯកសារ E9។

ក. សំណុំរឿង

៩. វិធាន ៨៦ ចែងថា ៖ "នៅគ្រប់ពេលវេលា សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីទាំងអស់ ត្រូវមានសិទ្ធិពិនិត្យមើល និងថត ចម្លងសំណុំរឿង ដោយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងនៅពេលម៉ោងធ្វើការ និងត្រូវគោរពទៅតាមលក្ខខណ្ឌតម្រូវសម្រាប់ដំណើរការល្អរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុង តុលាការកម្ពុជា"។

IV. **ឧទ្ធីករណ៍**

**ក. មេធាវីការពារក្តីមានសិទ្ធិទទួលបានប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ពីអង្គជំនុំជម្រះសាលាដំបូង ពីព្រោះជាការសមស្រប ប្រព័ន្ធគ្រប់គ្រងសំណុំរឿងត្រូវបានគេចាត់ទុកថាជាផ្នែកនៃសំណុំរឿង**

១០. មេធាវីការពារក្តីយល់ឃើញថា ប្រព័ន្ធគ្រប់គ្រងសំណុំរឿងរួមមានកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចស៊ើបសួរ ហើយបើយោងតាមនិយមន័យនៃ "សំណុំរឿង" នៅក្នុងវិធានផ្ទៃក្នុង ប្រព័ន្ធនេះត្រូវតែចាត់ទុកថាជាផ្នែកសំខាន់នៃសំណុំរឿង។ ដោយសារតែភាគីទាំងអស់មានសិទ្ធិថតចម្លងសំណុំរឿង[11] ដូច្នេះ ពួកគេក៏មានសិទ្ធិទទួលបានប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.សនេះដែរ។

១១. ពាក្យ "សំណុំរឿង" ភាសាអង់គ្លេសហៅថា Case File មានន័យថា "dossier" ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមរបស់វិធានផ្ទៃក្នុងថាសំដៅទៅដល់ "សំណុំឯកសារដែលរួមមានកំណត់ហេតុនៃកិច្ចដែលបានបំពេញនៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតបឋម ឬការស៊ើបសួរ ក៏ដូចជាពាក្យសុំរបស់ភាគី សេចក្តីសម្រេច ទាំងឡាយដែលបានចេញ និងអ្វីដែលជាឧបសម្ព័ន្ធដែលមាននៅក្នុងគ្រប់ដំណាក់កាលនីតិវិធី រួមទាំងកំណត់ហេតុសវនាការផង"។ ជា*កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចស៊ើបសួរ* សំណុំរឿងមានឯកសារពាក់ព័ន្ធទាំងអស់ រួមទាំង កំណត់ហេតុនៃការស្តាប់ចម្លើយ សារណា សេចក្តីសម្រេច និងការវិភាគ ដែលទាក់ទិននឹងការកំណត់នូវការពិតនៃអង្គហេតុទាំងឡាយដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ ក.ស.ព។

[11] វិធាន ៨៦(១)។

កំណត់ហេតុជាលាយលក្ខណ៍អក្សរទាំងនេះ តាមធម្មតារួមមានប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.សដែរ។

ខ. ការដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ទៅក្នុងសំណុំរឿង នឹងការពារសិទ្ធិរបស់ អៀង សារី ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលត្រូវជំនុំជម្រះឲ្យបានឆាប់រហ័ស និងមានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន

១. អង្គជំនុំជម្រះសាលាដំបូងអាចពិចារណាលក្ខណៈពិសេសរបស់ អ.វ.ត.ក នៅពេលធ្វើការបកស្រាយនូវសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ អៀង សារី

១២. វិធាន ២១ តម្រូវឲ្យមានការពិចារណាអំពី "លក្ខណៈពិសេស" របស់ អ.វ.ត.ក នៅពេលបកស្រាយលិខិតុបករណ៍ជាមូលដ្ឋានរបស់ អ.វ.ត.ក នៅក្នុងលក្ខណៈដែលការពារដល់ផលប្រយោជន៍របស់ អៀង សារី និងធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព។ អ.វ.ត.ក មានលក្ខណៈពិសេស ដោយសារតុលាការនេះមានកាតព្វកិច្ចធ្វើការជំនុំជម្រះរឿងក្តីឧក្រិដ្ឋកម្មសង្គ្រាមដែលមានលក្ខណៈទ្រង់ទ្រាយធំ និងមានភាពស្មុគស្មាញ ទោះបីជាដំណាក់កាលនៃការស៊ើបសួរត្រូវបានធ្វើឡើងក្រោមការត្រួតពិនិត្យផ្ទាល់មុខរបស់ ក.ស.ច.ស ក៏ដោយ។

១៣. កិច្ចស៊ើបសួរ (ដូច្នេះគឺសំណុំរឿងនេះ) មានវិសាលភាពខុសប្លែកពីគេ។ យោងតាមលោក Marcel Lemonde អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ សំណុំរឿង ០០២ គឺជាការជំនុំជម្រះបទល្មើសមួយដែលស្ថិតក្នុងចំណោមការជំនុំជម្រះនានាដ៏សែនស្មុគស្មាញបំផុត ចាប់តាំងពីមានការជំនុំជម្រះនៅឯតុលាការ Nuremberg[12]។ ជាមួយនឹងឯកសារចំនួនជាង ៧០.០០០ ដែលត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ពិសេសដោយធនធានមានកំណត់ យើងឃើញថា ក.ស.ច.ស ហាក់ដូចជាគ្មានលទ្ធភាពគ្រប់គ្រាន់ខាងផ្នែកបច្ចេកទេស និងនៅពុំទាន់សូវមានប្រសិទ្ធផលនៅឡើយទេ ក្នុងការបង្កើតសំណុំឯកសារមួយដែលធ្លាប់គេប្រើប្រាស់ពីដើមរៀងមក ដែលតំណាងឲ្យសំណុំរឿង ១ (និយាយឲ្យចំគឺសំណុំឯកសារមួយ) ដែលក្នុងនោះមានឯកសារ និងសេចក្តីវិភាគក្នុងទម្រង់ជាក្រដាសស្នាមដែលប្រមូលបានក្នុងអំឡុងកិច្ចស៊ើបសួរ។ ក.ស.ច.ស បានប្រើប្រាស់ Zylab ដែលជាមូលដ្ឋានទិន្នន័យគ្រឹះអេឡិចត្រូនិកដើម្បីរក្សាទុកឯកសារដែលត្រូវបានដាក់បញ្ចូលបន្ថែមទៅក្នុងសំណុំរឿង និងដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការឲ្យភាគីអាចពិនិត្យឯកសារនៃសំណុំរឿងទាំងនោះបាន[13]។ ដូច្នេះ ពុំមែនជាការខុសឆ្គងឡើយក្នុងការសន្និតថា ក.ស.ច.ស បានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងសំណុំរឿងដើម្បីកត់ត្រាថាតើឯកសារនៅក្នុងសំណុំរឿងពាក់ព័ន្ធដូចម្តេចទៅនឹង "អង្គហេតុ" "កម្មវត្ថុ" និង "បញ្ហា" នានា (ដូចដែលបានកំណត់ខាងលើ) ដែលខ្លួនយល់ថាពាក់ព័ន្ធនឹងសំណុំរឿងនេះ។ ដោយហេតុថាប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស គឺជាឧបករណ៍សំខាន់មួយសម្រាប់បង្កើត *កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចស៊ើបសួរ* អង្គជំនុំជម្រះសាលាដំបូងគួរដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿងនេះ ទៅក្នុងសំណុំរឿង ហើយអនុញ្ញាតឲ្យភាគីពិនិត្យមើលបាន។

១៤. អ.វ.ត.ក ខុសប្លែកពីតុលាការឧក្រិដ្ឋកម្មសង្គ្រាមដទៃទៀត ត្រង់ថា កិច្ចស៊ើបសួរត្រូវបានអនុវត្តក្រោមការត្រួតពិនិត្យផ្តាច់មុខរបស់សហចៅក្រមស៊ើបអង្កេត។ ភាគីពុំមានសិទ្ធិបើកកិច្ចស៊ើបសួរដោយខ្លួន

---

[12] *សូមមើល* Julia Wallace, មេដឹកនាំជាន់ខ្ពស់ចំនួន ៤ រូបដែលត្រូវបានចោទប្រកាន់ និងបញ្ជូនរឿងទៅជំនុំជម្រះ នឹងទទួលការជំនុំជម្រះ, CAMBODIA DAILY, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១០។

[13] វិធាន ៥៥(៦)។ *សូមមើលផងដែរ* វិធាន ៥៥(១១), ដែលអនុលោមតាមវិធាននេះ ភាគីមានសិទ្ធិសុំមើលសំណុំរឿងច្បាប់ដើម។

ឯងឡើយ[14]។ ក.ស.ច.ស ត្រូវបានបង្កើតឡើងដើម្បីបំពេញមុខងារដោយឯករាជ្យមិនលម្អៀង[15] ដោយមានភារកិច្ច "ចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត"[16]។ ខុសពីតុលាការ *មិនអចិន្ត្រៃយ៍* និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ដែលភាគីជាអ្នកបំពេញកិច្ចស៊ើបសួរដោយខ្លួនឯង នៅ អ.វ.ត.ក មាន ក.ស.ច.ស ជាអ្នកទទួលបន្ទុកថែរក្សាឯកសារសំណុំរឿង រួមទាំង*កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចស៊ើបសួរ* ផង[17]។ ក្នុងការបំពេញកិច្ចស៊ើបសួរ ក.ស.ច.ស មិនបាន ហើយគួរតែមានកម្មវិធីជាក់លាក់មួយ ប៉ុន្តែត្រូវបំពេញកិច្ចស៊ើបសួរដោយមិនលម្អៀង។ ដូច្នេះនៅក្នុងប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ខ្លួន ក.ស.ច.ស ពុំអាចមានទ្រឹស្តីណាមួយ ដែលអាចបង្ហាញនូវមធ្យោបាយ ឬយុទ្ធសាស្ត្រនានាដើម្បីផ្តល់ផលប្រយោជន៍ដល់ភាគីណាមួយឡើយ។ ប៉ុន្តែ ប្រសិនបើប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស *មាន* ព័ត៌មានបែបនេះ យើងអាចសន្និដ្ឋានបានថា ភាគីនឹងមានសិទ្ធិពិនិត្យទិន្នន័យទាំងនោះ ដោយហេតុថាវាអាចប៉ះពាល់ដោយផ្ទាល់ទៅដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះ *លើអង្គសេចក្តី* ដោយយុត្តិធម៌ ដោយសារតែការបង្ហាញនូវចំណុចខ្សោយនៅក្នុងសុចរិតភាពនៃសំណុំរឿង[18]។

### ២. ការដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ទៅក្នុងសំណុំរឿង នឹងជួយសម្រួលកិច្ចដំណើរការនីតិវិធីឱ្យបានឆាប់រហ័ស

---

[14] ចម្លើយតបទៅនឹងលិខិតរបស់លោកចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧ ពាក់ព័ន្ធនឹងការបំពេញកិច្ចស៊ើបសួរ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨, ឯកសារលេខ A110/I, ទំព័រ ២។ *សូមមើលផងដែរ* ដីកាសម្រេចធ្វើការព្រមាន ដោយអនុវត្តតាមវិធាន ៣៨, ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១០, ឯកសារលេខ D367។

[15] ច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក, មាត្រា ២៥, កិច្ចព្រមព្រៀង, មាត្រា ៥, *សូមមើលផងដែរ* វិធាន ១៤(១)។

[16] វិធាន ៥៥(៦)។

[17] ដូចជើងទំព័រខាងលើ។

[18] *សូមមើល* មាត្រា ២៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលចែងថា "វិធាន និងទម្រង់ការដែលមានបំណងធានាការគោរពសិទ្ធិការពារខ្លួនមានលក្ខណៈសំខាន់"។ *សូមមើលផងដែរ* វិធាន ៧៦(៧)៖ "លើកលែងតែជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការសួរស៊ើបសួរ។ គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះ អាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូល"។

Original EN: 00700055-00700063

១៥. យើងត្រូវដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ទៅក្នុងសំណុំរឿង ដើម្បីជួយសម្រួលកិច្ចដំណើរការនីតិវិធីឲ្យបានឆាប់រហ័ស[19]។ ការដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿងទៅក្នុងសំណុំរឿងនឹងអនុញ្ញាតឲ្យភាគីអាចពិនិត្យវិធីសាស្ត្ររបស់ ក.ស.ច.ស ក្នុងការភ្ជាប់ទំនាក់ទំនងរវាងឯកសារ, បុគ្គល និងហេតុការណ៍ផ្សេងៗ ទៅនឹងបញ្ហាជាក់លាក់ដែលមាននៅក្នុងសំណុំរឿងនេះ។ ប្រសិនបើភាគីបានដឹងព័ត៌មាននេះ ភាគីនឹងមានលទ្ធភាពផ្តោតការយកចិត្តទុកដាក់ទៅលើឯកសារ, បុគ្គល និងហេតុការណ៍ទាំងប៉ុន្មាននេះ នៅពេលខ្លួនរៀបចំសំណួរសម្រាប់សួរសាក្សី។ ក្នុងចំណោមប្រការផ្សេងៗ ចំណុចនេះនឹងជួយឲ្យការសួរសំណួរសាក្សីមានភាពជាក់លាក់ពាក់ព័ន្ធនឹងបញ្ហាដែលកំពុងស្ថិតក្រោមការពិចារណា។ ដោយពិចារណាទៅលើលក្ខណៈពិសេសប្លែកពីគេរបស់ អ.វ.ត.ក នេះ ការដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ទៅក្នុងសំណុំរឿង នឹងរួមចំណែកមួយភាគធំដល់ការអនុវត្តកិច្ចដំណើរការនីតិវិធីឲ្យបានឆាប់រហ័ស។

### ៣. ការដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ទៅក្នុងសំណុំរឿង នឹងការពារសិទ្ធិរបស់ អៀង សារី ក្នុងការមានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ដើម្បីរៀបចំការការពារខ្លួន

១៦. យើងត្រូវដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ទៅក្នុងសំណុំរឿងដើម្បីការពារសិទ្ធិរបស់លោក អៀង សារី ក្នុងការមានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ដើម្បីរៀបចំការការពារខ្លួន[20]។ ការដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ទៅក្នុងសំណុំរឿង ធ្វើឲ្យយើងចំណេញម៉ោងធ្វើការច្រើន ដែលនឹងអនុញ្ញាតឲ្យភាគីអាចពិនិត្យមើល*កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចស៊ើបសួរ* ទាំងស្រុង រួមទាំងវិធីសាស្ត្ររបស់ ក.ស.ច.ស ក្នុងការភ្ជាប់ទំនាក់ទំនងឯកសារ, អង្គហេតុ និងបញ្ហានានានៅក្នុងសំណុំរឿងនេះ។

---

[19] ច្បាប់ស្តីពីការបង្កើតឲ្យមាន អ.វ.ត.ក, មាត្រា ៣៣ ថ្មី។

[20] *សូមមើល* កិច្ចព្រមព្រៀង, មាត្រា ១៣(១), ច្បាប់ស្តីពីការបង្កើតឲ្យមាន អ.វ.ត.ក, មាត្រា ៣៥ ថ្មី, កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ១៤(៣), សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស, មាត្រា ១១(១)។

Original EN: 00700055-00700063

១៧. ការដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ទៅក្នុងសំណុំរឿង នឹងអនុញ្ញាតឲ្យភាគីអាចវិភាគអំពីការវាយតម្លៃរបស់ ក.ស.ច.ស ទៅលើសំណុំរឿងទាំងមូលជាលក្ខណៈប្រព័ន្ធនៅមុនពេល និងអំឡុងពេលនៃកិច្ចជំនុំជម្រះ។ ឯកសារចំនួន ១.៧៦២ ក្នុងចំណោមឯកសារជាង ៧០.០០០ ដែលត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ត្រូវបានដីកាដំណោះស្រាយលើកយកមកធ្វើជាសំអាង។ មានតែតាមរយៈការដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ក.ស.ច.សទៅក្នុងសំណុំរឿងប៉ុណ្ណោះ ទើបភាគីអាចមានលទ្ធភាពយល់អំពីវិធីសាស្ត្ររបស់ ក.ស.ច.ស ក្នុងការវាយតម្លៃសំណុំរឿង *ទាំងមូល* រួមទាំងការពិចារណារបស់ ក.ស.ច.ស ទៅលើលក្ខណៈដាក់បន្ទុក ឬដោះបន្ទុកនៃឯកសារចំនួនប្រមាណ៦៨.០០០ ដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ហើយដែលដីកាដំណោះស្រាយពុំបានលើកយកមកធ្វើជាសំអាង។ ការដាក់ប្រព័ន្ធគ្រប់គ្រងសំណុំរឿងចូលទៅក្នុងសំណុំរឿងនឹងជាមធ្យោបាយចាំបាច់មួយ ដើម្បីធានាបាននូវសុចរិតភាពនៃកិច្ចស៊ើបសួរ តាមរយៈការជួយបញ្ជាក់ថាអ្វីទាំងអស់ដែលប្រមូលបានពីកិច្ចស៊ើបសួររយៈពេល ២ ឆ្នាំកន្លះក្នុងសំណុំរឿង ០០២ នេះ ត្រូវបានលើកយកមកធ្វើជាសំអាងនៅពេលជំនុំជម្រះ។ នៅក្នុងបរិបទនៃប្រព័ន្ធដដែកសួរដេញដោលដោយចៅក្រមនៅ អ.វ.ត.ក ដែលក្នុងនោះចៅក្រមមានភារកិច្ចស្វែងរកការពិតមិនលម្អៀង ការដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ទៅក្នុងសំណុំរឿង នឹងជួយលើកកម្ពស់សមត្ថភាពរបស់មេធាវីការពារក្តីក្នុងការផ្តោតការយកចិត្តទុកដាក់ទៅលើការសួរសំណួររបស់ខ្លួន ដែលអាចជួយច្រើនដល់កិច្ចការចោទសួរសាក្សីរបស់អង្គជំនុំជម្រះសាលាដំបូង។ ដោយពិចារណាទៅលើលក្ខណៈពិសេសដោយឡែករបស់ អ.វ.ត.ក ការដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ទៅក្នុងសំណុំរឿង មានភាពចាំបាច់ដើម្បីគាំពារសិទ្ធិរបស់ លោក អៀង សារី ក្នុងការមានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ដើម្បីរៀបចំការការពារខ្លួន។

**គ. ប្រសិនបើប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ត្រូវបានផ្តល់ទៅឲ្យអង្គជំនុំជម្រះសាលាដំបូង នេះបញ្ជាក់ថា ប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស គឺជាផ្នែកនៃសំណុំរឿង ហើយភាគីមានសិទ្ធិពិនិត្យមើលបាន**

១៩. មេធាវីការពារក្តីដឹងថា អតីតបុគ្គលិកបច្ចេកទេសរបស់ ក.ស.ច.ស អាចត្រូវបានផ្ទេរទៅកាន់អង្គជំនុំជម្រះសាលាដំបូងដើម្បីជួយបង្កើតប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់អង្គជំនុំជម្រះសាលាដំបូង។

មេធាវីការពារក្តីសន្មតថា បុគ្គលិកដែលបានផ្ទេរការងារនេះត្រូវបានរក្សាទុកក្នុងតួនាទីបច្ចេកទេសដែលពុំមែនជាតួនាទីវិភាគ (ឧទាហរណ៍ដូចជា ផ្នែកច្បាប់ និង/ឬអង្គហេតុអង្គសេចក្តី) ឡើយ។ ដូច្នេះ មេធាវីការពារក្តីសូមសន្មតទៀតថា ពុំមានការរំលោភណាមួយឡើយលើវិធានជាធរមាននៃក្រមវិជ្ជាជីវៈ និងបទបញ្ញត្តិផ្សេងៗដែលទប់ស្កាត់ជម្លោះផលប្រយោជន៍ និងការរំលោភការសម្ងាត់[21]។ ប្រសិនបើមានការផ្ទេរបុគ្គលិកណាម្នាក់ដែលមានតួនាទីជាអ្នកវិភាគពីស្ថាប័នមួយទៅស្ថាប័នមួយទៀត (ឬពីផ្នែកមួយទៅផ្នែកមួយទៀត) នៅ អ.វ.ត.ក (ឧទាហរណ៍ ការផ្ទេរបុគ្គលិកពី ក.ស.ច.ស ទៅអង្គភាពគាំពារការការពារក្តី) ពិតណាស់ ការផ្ទេរនេះនឹងនាំឱ្យមានកង្វល់យ៉ាងខ្លាំងថាអាចមានការរំលោភទៅលើវិធាននៃក្រមវិជ្ជាជីវៈទាំងនេះ។ ទោះបីបុគ្គលិករូបនោះបានផ្ទេរមកបំពេញការងារផ្នែកវិភាគ ឬផ្នែកបច្ចេកទេសក្តី ក៏ជាការសមស្របក្នុងការគិតទុកជាមុនថា បុគ្គលិកដែលផ្ទេរការងារពីស្ថាប័នមួយទៅស្ថាប័នមួយ (ឬពីផ្នែកមួយ ទៅផ្នែកមួយ) នៅ អ.វ.ត.ក នឹងពាំនាំយកទៅជាមួយនូវចំណេះដឹង និងការចងចាំ ដែលខ្លួនមានក្នុងតួនាទីមុន។ យើងមិនអាចជឿបានឡើយថា បុគ្គលិកម្នាក់នេះនឹងមិនយកចំណេះដឹង និងការចងចាំរបស់ខ្លួនទៅអនុវត្តក្នុងតួនាទីថ្មី។

២០. ប្រសិនបើសព្វថ្ងៃ អង្គជំនុំជម្រះសាលាដំបូងកំពុងពឹងផ្អែកទៅលើចំណេះដឹងពីស្ថាប័នមុនរបស់បុគ្គលិកផ្ទេរចូលថ្មីនេះ ឬប្រសិនបើប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ត្រូវបានផ្តល់ឱ្យអង្គជំនុំជម្រះសាលាដំបូងវិញ[22] ចំណុចនេះគាំទ្រទស្សនៈរបស់មេធាវីការពារក្តីដែលថាយើងគួរចាត់ទុកប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ថាជាផ្នែកមួយនៃសំណុំរឿង[23]។ យើងអាចយល់បានថា អង្គជំនុំជម្រះសាលាដំបូងពឹងផ្អែកលើប្រព័ន្ធមួយនេះ ឬយ៉ាងហោចណាស់ក៏នឹងប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងសំណុំរឿងដែលបង្កើតឡើងដោយ ក.ស.ច.ស ដោយហេតុថាប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.

---

[21] *សូមមើល* ក្រមសីលធម៌នៃមេធាវីដែលបានចុះក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមសីលធម៌មេធាវីកម្ពុជា"), មាត្រា ៦១, ក្រមសីលធម៌គណៈមេធាវីអន្តរជាតិ, វិធាន ១៣, វិធាន ៥៦(១), សេចក្តីណែនាំអនុវត្តស្តីពីការដាក់ចំណាត់ថ្នាក់ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង, មាត្រា ៨, លិខិតសន្យាដែលមានហត្ថលេខារបស់បុគ្គលិក អ.វ.ត.ក ដែលបានអនុញ្ញាតឱ្យមានការពិនិត្យសំណុំរឿង និង Zyimage, ក្រមសីលធម៌មេធាវីកម្ពុជា, មាត្រា ៧, ច្បាប់កម្ពុជាស្តីពីគណៈមេធាវី, មាត្រា ៥៨, ក្រមសីលធម៌គណៈមេធាវីអន្តរជាតិ, វិធាន ១៤។

[22] *សូមមើលឯកសារយោងខាងលើ* ត្រង់កថាខណ្ឌ ៨។

[23] *សូមមើលឯកសារយោងខាងលើ* ត្រង់ផ្នែក IV.ក។

Original EN: 00700055-00700063

ច.ស អាចជាឯកសារដើម ដូចជា *កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចស៊ើបសួរ* ដែលជាមូលដ្ឋាននៃដីកាដំណោះស្រាយ។ ការធ្វើបែបនេះអាចឲ្យយើងសន្សំសំចៃធនធានតុលាការ និងបញ្ចៀសភាពច្រំដែល។ អង្គជំនុំជម្រះសាលាដំបូងក៏អាចទទួលផលប្រយោជន៍ផងដែរពីចំណេះដឹងពីស្ថាប័នមុនរបស់បុគ្គលិកផ្នែកបច្ចេកទេស និងអាចបញ្ចៀសកំហុសឆ្គងណាមួយដែល ក.ស.ច.ស អាចធ្លាប់មាននៅក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ខ្លួន។ ទោះបីជាយ៉ាងដូច្នេះក្តី ក.ស.ច.ស (ក្នុងនាមជាស្ថាប័នតុលាការឯករាជ្យ) ពុំអាចគេចវេសបានឡើយពីនីតិវិធីដែលបានបង្កើតឡើងដើម្បីរក្សាសុចរិតភាពនៃសំណុំរឿងតាមរយៈការប្រគល់*កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចស៊ើបសួរ* ឧទាហរណ៍ដូចជាប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ខ្លួន ជូនអង្គជំនុំជម្រះសាលាដំបូងដោយមិនបានបញ្ជាក់ជាមុនថា កំណត់ហេតុទាំងនោះត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង និងបានជូនដំណឹងដល់ភាគីរួចហើយនោះទេ។

២១. កង្វល់ណាមួយដែលថាប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស គឺជាឯកសារសម្ងាត់ផ្ទៃក្នុង ដែលពុំគួរដាក់បញ្ចូលទៅក្នុងសំណុំរឿង នឹងត្រូវបានបង្ហាញថាជាកង្វល់ពុំសមហេតុផល ដោយសារ ក.ស.ច.ស មានចេតនាចែករំលែកប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ខ្លួនទៅឲ្យអង្គជំនុំជម្រះសាលាដំបូង។ ប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ពុំមែនជាឯកសារ ឬការប្រាស្រ័យទាក់ទងសម្ងាត់ឡើយ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងពិតជាបានទទួលប្រព័ន្ធគ្រប់គ្រងសំណុំរឿងពី ក.ស.ច.ស មែន នោះអង្គជំនុំជម្រះសាលាដំបូងគួរដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿងនេះ ទៅក្នុងសំណុំរឿង និងប្រគល់ឲ្យភាគី ស្របតាមនីតិវិធីចោទសួរដេញដោលដោយចៅក្រមដែលមានស្រាប់។ ពុំគួរមានឡើយការផ្ទេរ *កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចស៊ើបសួរ* ណាមួយពី ក.ស.ច.ស ទៅអង្គជំនុំជម្រះសាលាដំបូង ដោយពុំមានការជូនដំណឹងឲ្យភាគីបានដឹង។ និយាយឲ្យងាយយល់ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិពិនិត្យមើលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ភាគីក៏មានសិទ្ធិពិនិត្យមើលដែរ[24]។

---

[24] ដើម្បីបញ្ចៀសវិមតិសង្ស័យ បញ្ហាថាតើមេធាវីការពារក្តីមានសិទ្ធិពិនិត្យមើលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស នៅដំណាក់កាលជំនុំជម្រះពុំត្រូវបានដោះស្រាយ។ នេះជាបញ្ហាថ្មី។ ទោះបី ក.ស.ច.ស បានបដិសេធសំណើរបស់មេធាវីការពារក្តីស្នើសុំពិនិត្យមើលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ខ្លួនក្នុងអំឡុងដំណាក់កាលស៊ើបសួរ និងបានព្រមានអំពីការដាក់ឯកសារច្រំដែលក្តី (ពាក់

អាស្រ័យហេតុនេះ តាមហេតុផលដូចដែលបានបញ្ជាក់ខាងលើ មេធាវីការពារក្តីសូមគោរពស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង មេត្តាដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ទៅក្នុងសំណុំរឿងដោយក្តីអនុគ្រោះ។

សូមថៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១១

________________ ________________

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីរបស់លោក **អៀង សារី**

---

ព័ន្ធនឹងបញ្ហានេះ *សូមមើល* ឯកសារយោងខាងលើ លេខ ៦), ក៏ស្ថានភាពនៅពេលនេះខុសពីពេលមុន។ នៅពេលនេះ អង្គជំនុំជម្រះសាលាដំបូងបានដឹង និងកំពុងជួបប្រទះនឹងបញ្ហាថាតើភាគីមានសិទ្ធិពិនិត្យមើលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ជាលើកទីមួយដែរ ឬទេ ក្នុងដំណាក់កាលជំនុំជម្រះ។

Original EN: 00700055-00700063